# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Feb-2012, 12:34
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ:/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# បណ្តឹងជំទាស់ចិត្តលើកទីបីចំពោះចៅក្រម CARTWRIGHT

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

## I. សេចក្តីផ្តើម

១. អនុលោមតាមមាត្រា ៥៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងមាត្រា ៣៥ នៃវិធានផ្ទៃក្នុង អវតក ("វិធានផ្ទៃក្នុង") មេធាវីការពារក្តីជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្តី") ដាក់បណ្តឹងជំទាស់នេះចំពោះចៅក្រម Silvia Cartwright ពីដំណើរការនីតិវិធីទាំងអស់នៅក្នុងករណី ០០២។ សម្រាប់មូលហេតុទាំងអស់ដែលបញ្ជាក់នៅខាងក្រោម ក្រុមមេធាវីការពារក្តីស្នើឲ្យពិចារណាថា: (i) បណ្តឹងជំទាស់នេះអាចទទួលយកបាន, (ii) ចៅក្រម Cartwright ត្រូវតែ (ឬយ៉ាងហោចណាស់គប្បី) លាលែងដោយរង់ចាំដំណោះស្រាយលើបណ្តឹងជំទាស់នេះសិន និង (iii) ការកត់សម្គាល់ថ្មីៗនេះរបស់លោកស្រីចៅក្រមទៅកាន់សារព័ត៌មានញូហ្ស៊ីឡែនបង្ហាញពីភាពលម្អៀងប្រឆាំងនឹង នួន ជា និងជាជម្រើស នឹងនាំឲ្យអ្នកអង្កេតការមិនលំអៀង និងដែលត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវ មើលឃើញពីភាពលម្អៀងរបស់លោកស្រីចៅក្រម ។ ដោយពិចារណាពីសារៈសំខាន់ផ្នែកច្បាប់ដែលបានលើកឡើងនៅទីនេះ និងផលប្រយោជន៍ទូទៅនៅក្នុងដំណើរការនីតិវិធីជំនុំជម្រះ បណ្តឹងជំទាស់នេះត្រូវតែបានចំណាត់ថ្នាក់ជាសាធារណៈ។ ទោះជាក្នុងកាលៈទេសៈណាក៏ដោយក្រុមមេធាវីការពារក្តីចាត់ទុកបណ្តឹងជំទាស់នេះថាជាឯកសារសាធារណៈ [1]។

## II. អង្គហេតុពាក់ព័ន្ធ

២. កាលពីថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ព័ត៌មានខាងក្រោមនេះត្រូវបានចុះផ្សាយនៅក្នុងសារព័ត៌មានញូហ្ស៊ីឡែន

> [...] លោកស្រី Cartwright ជាចៅក្រមអន្តរជាតិម្នាក់ក្នុងចំណោមចៅក្រមអន្តរជាតិពីរនាក់អមជាមួយចៅក្រមកម្ពុជាបីនាក់នៅអង្គជំនុំជម្រះសាលាដំបូង ដែលកាលពីឆ្នាំ២០១០ សម្រេចឲ្យ ឌុច មានពិរុទ្ធភាព ។
>
> លោកស្រីរស់នៅទីក្រុងភ្នំពេញដែលក្តៅ សំណើម និងជាទីក្រុងរញ៉េរញ៉ៃតាំងតែពីឆ្នាំ ២០០៨ មកម្ល៉េះ បានរៀបរាប់ពីបទពិសោធន៍របស់លោកស្រីនៅតុលាការថា "គួរឲ្យចាប់ចិត្ត ព្រមទាំងមិនស្រួលសប្បាយក្នុងចិត្តផងដែរ" ។

[1] សូមមើលកថាខណ្ឌទី ១១ ខាងក្រោម ។

ខណៈជាមន្ត្រីជាន់ខ្ពស់បំផុតដែលតែងតាំងដោយអង្គការសហប្រជាជាតិ លោកស្រី Cartwright យល់ឃើញថា វាជាការទទួលខុសត្រូវរបស់លោកស្រី មិនត្រឹមតែធ្វើឱ្យប្រាកដថា ការជំនុំជម្រះត្រូវតែធ្វើឡើងប្រកបដោយប្រសិទ្ធិភាព ហើយស្របពេលជាមួយគ្នាតុលាការ ក៏ត្រូវគ្រប់គ្រងប្រកបដោយស្មោះត្រង់ និងវិជ្ជាជីវៈដែរ។ ប៉ុន្តែវាមិនអាចកើតឡើងដោយមិនមានការជំទាស់ និងភាពចម្រូងចម្រាស់ឡើយ ។

មេធាវីការពារក្តីបានរិះគន់គាត់ជាសាធារណៈកាលពីឆ្នាំមុន អំពីការដែលគាត់បានជួបប្រជុំជាមួយព្រះរាជអាជ្ញា ដែលគាត់សារភាពថាបានធ្វើដូច្នេះមែន ដោយសារតែមានជម្រើសតិចតួច ។

***លោកស្រីមានប្រសាសន៍ថា៖ "មេធាវីការពារក្តីបានផ្តោតការយកចិត្តទុកដាក់ពីការខ្វែង ជា ជាងការការពារក្តីកូនក្តីរបស់ពួកគេ" ។***

*"វាជាយុទ្ធសាស្ត្រធម្មតារបស់មេធាវីការពារក្តី។ មានពាក្យបណ្តឹងមួយដោយបានចោទប្រកាន់ មកលើរូបខ្ញុំពីរដង ម្តងជាសមាជិកនៃអង្គជំនុំជម្រះទាំងមូល និងម្តងជារឿងបុគ្គល ហើយក៏មានបណ្តឹងមួយទៀតចោទប្រកាន់ប្រឆាំងប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលជាចៅក្រមកម្ពុជា និងចៅក្រមកម្ពុជាដទៃទៀតផងដែរ" ។*

លោកស្រី Cartwright កាលពីរឆ្នាំមុនត្រូវបានអង្គការសហប្រជាជាតិស្នើឱ្យកោះប្រជុំទៀងទាត់ជាមួយភាគីដទៃទៀត ដើម្បី"ពិភាក្សាបញ្ហាគ្រប់គ្រងសវនាការ"។ ពេលខ្លះគាត់ប្រឆាំងនឹងការប្រជុំនេះដែរ តែក្រោយមកទើបដឹងថាវាជាបញ្ហាសំខាន់ ដូច្នេះយើងត្រូវជួបប្រជុំគ្នាដើម្បីពិភាក្សាបញ្ហាសំខាន់ៗ ដូចជាថវិកាសម្រាប់តុលាការ បញ្ហាបុគ្គលិក បញ្ហា IT ជាដើម។ សំខាន់បំផុតនោះគឺបញ្ហាគ្រប់គ្រងសវនាការដែលប៉ះពាល់ដល់ការជំនុំជម្រះ"[2] ។

---

[2] Michelle Cooke "កម្ពុជានៅតែស្រាវពីខ្មែរក្រហម 'Cambodia still reeling from Khmer Rouge', Stuff New Zealand (Fairfax NZ News), ចុះផ្សាយថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១២ (available at http://www.stuff.co.nz/world/asia/6367143/Cambodia-still-reeling-from-Khmer-Rouge)" (បញ្ជាក់បន្ថែម) ។

អត្ថបទសារព័ត៌មាននេះមាននៅក្នុង press clipping របស់ អវតក នៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១២[3]។ ក្នុងចំណោមបញ្ហាផ្សេងទៀត វាត្រូវតែបានសន្មត់ថា ការលើកឡើងរបស់ចៅក្រម Cartwright គឺត្រូវបានធ្វើឡើងមកលើក្រុមមេធាវីការពារក្ដីរបស់លោក នួន ជា។

៣. ប៉ុន្មានថ្ងៃមុននេះ ក្នុងការឆ្លើយតបទៅនឹងការប៉ុនប៉ងចំរាញ់យកសក្ខីកម្មពីសាក្សី ប្រាក់ យុទ្ធ ចៅក្រម Cartwright លើកឡើងថាក្រុមមេធាវីការពារក្ដីយល់ខុសពីតួនាទីរបស់ខ្លួននៅក្នុងករណីនេះ ហើយកំពុងតែធ្វើសកម្មភាពប្រឆាំងនឹងផលប្រយោជន៍របស់ នួន ជា:

> ចៅក្រម Cartwright ដោយមានការអនុញ្ញាតពីលោកប្រធាន ខ្ញុំនឹងប្រាប់លោកជាភាសាអង់គ្លេស ខណៈលោកកំពុងតែស្វែងរក headphones ថ្មីនោះ។ លោកប្រធានបានសម្រេចពីរលើក រួចមកហើយថា លោកត្រូវតែស្ថិតនៅក្នុងវង្វង់ការជំនុំជម្រះវគ្គទី ២ និងការជំនុំជម្រះលើកដំបូងនៅក្នុងការជំនុំជម្រះវគ្គទី២។ ថាតើលោកយល់ច្បាស់ហើយឬនៅ១ពេលនេះលោកមេធាវី? លោក PESTMAN: សំណួររបស់ខ្ញុំគឺឋិតក្នុងវង្វង់នៃវិសាលភាពនៃការជំនុំជម្រះលើកដំបូង- ចៅក្រម Cartwright: សូមកុំតវ៉ា ។ លោកត្រូវបានស្នើសុំឱ្យតាំងសំណួរបន្ទាប់របស់លោក អរគុណ។ លោក PESTMAN: ខ្ញុំសូមធ្វើការកត់សំគាល់ចំពោះកំណត់ត្រាថាខ្ញុំមិនយល់ស្របនឹងសេចក្ដីសម្រេចនេះទេ។ ខ្ញុំនៅទីនេះចង់លើកឡើងពីការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលនៅក្នុងករណី ០០២ ហើយសម្រាប់គោលបំណងនេះ ខ្ញុំសួរសំណួរទាំងនេះ ហើយខ្ញុំគិតថាសំណួរទាំងនេះឋិតនៅក្នុងវង្វង់នៃវិសាលភាពនៃករណីនេះ គឺករណី ០០២ ប៉ុន្តែ ខ្ញុំនឹងបន្តតាំងសំណួររបស់ខ្ញុំទៅទៀត ។ ចៅក្រម Cartwright: **ខ្ញុំយល់ថាតួនាទីរបស់លោកនៅទីនេះ គឺតំណាង និងការពារកូនក្ដីរបស់លោក**។ សូមលោកតាំងសំណួរបន្ទាប់ ដែលពាក់ព័ន្ធនឹងការជំនុំជម្រះនេះ ។ អរគុណ[4] ។

ការកត់សម្គាល់របស់ចៅក្រម Cartwright ត្រូវបានផ្សព្វផ្សាយជាសារណៈ និងនៅចំពោះមុខជនជាប់ចោទផងដែរ ។

៤. ដោយពិចារណាពីពេលវេលា និងភាពស្រដៀងគ្នានៃការកត់សម្គាល់របស់លោកស្រីចៅក្រម Cartwright នៅក្នុងតុលាការនិងក្រៅតុលាការ

---

[3] សូមមើល ECCC Media Clipping: 4-6 ខែកុម្ភៈ ឆ្នាំ២០១២ នៅទំព័រ ៦៨ ។ (ផ្ដល់ឱ្យដោយផ្នែកកិច្ចការសាធារណៈថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ២០១២ ។

[4] ឯកសារ E-1/35.1 ប្រតិចារិតនៃដំណើរការជំនុំជម្រះ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ (សវនាការថ្ងៃ២៣) ទំព័រ ៧៥ ១៧-៧៦:១៣ ។ (បញ្ជាក់បន្ថែម) ។

នោះវាបង្ហាញយ៉ាងច្បាស់ថាការលើកឡើងដោយលោកស្រីចៅក្រម Cartwright នៅខាងក្រៅតុលាការគឺពិតជាសំដៅមកលើក្រុមមេធាវីការក្ដី នួន ជា ។

## III. ច្បាប់ដែលពាក់ព័ន្ធ

### ក.អនាគតិតុលាការ

៥. មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាតម្រូវឱ្យតុលាការមិនលម្អៀង៖ "អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ"។ ទស្សនទានដ៏សំខាន់នេះមានចែងនៅក្នុងកិច្ចព្រមព្រៀង និងច្បាប់បង្កើត អវតក ដែលចែងថាចៅក្រម "ត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលំអៀង និងសុចរិត និងមានគុណសម្បត្តិ"[5]។ ការធានាដូចគ្នានេះ មានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិមនុស្ស និងសិទ្ធិនយោបាយ ('ICCPR')[6] អនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស (ECHR)[7] អនុសញ្ញាអាមេរិកស្ដីពីសិទ្ធិមនុស្ស[8] ធម្មនុញ្ញអាហ្វ្រិកស្ដីពីមនុស្ស និងសិទ្ធិមនុស្ស[9] ព្រមទាំងលក្ខន្តិកៈរបស់តុលាការ ICC[10] តុលា

---

[5] មាត្រា ៣(៣) នៃកិច្ចព្រមព្រៀង អវតក ។ សូមមើលផងដែរមាត្រា ១០ថ្មី នៃច្បាប់បង្កើត អវតក ("ចៅក្រមនៅអង្គជំនុំជម្រះ... មានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលំអៀង និងសុចរិត [...].) ។

[6] មាត្រា ១៤(១) ("ជនគ្រប់រូប មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈដោយតុលាការមានសមត្ថភាពមាន និង ឥតលំលៀង ដែលបង្កើតឡើងដោយច្បាប់") ។

[7] មាត្រា ៦(១) "ជនគ្រប់រូបមានសិទ្ធិ មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈក្នុងពេលវេលាសមស្របដោ យតុលាការមានសមត្ថភាពមាន និង ឥតលំលៀងដែលបង្កើតឡើងដោយច្បាប់") ។

[8] មាត្រា ៨(១) "ជនគ្រប់រូបមានសិទ្ធិទទួលបានជំនុំជម្រះ ដោយមានការធានាតាមច្បាប់ និងក្នុងពេលវេលាសមស្របដោយតុលាការមានសមត្ថភាព, ឯករាជ្យ និងឥតលំអៀង ។

[9] មាត្រា ៧(១) ""ជនគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះលើបុព្វហេតុរបស់ខ្លួន ។ សិទ្ធិនេះរួមបញ្ចូលទាំង [...] (ឃ) សិទ្ធិត្រូវកាត់សេចក្ដីក្នុងពេលវេលាសមស្របដោយតុលាការឯករាជ្យ និងឥតលំអៀង ។ សូមមើលឧទាហរណ៍គំរោងសិទ្ធិតទល់ជាមួយប្រទេសនីហ្សេរី, គណៈកម្មាធិការសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអាហ្វ្រិក សំណុំរឿង ៨៧/៩៣)(១៩៩៥) សេចក្ដីសម្រេចនៅកថាខណ្ឌទី១៤ (ដោយមិនគិតដល់ចរិតលក្ខណៈរបស់សមាជិករបស់តុលាការ គ្រាន់តែសមាភាពរបស់វាប៉ុណ្ណោះ បង្កើតឱ្យឃើញនូវភាពអនាគតិរួចហើយ ។ ដូច្នេះវារំលោភមាត្រា ៧.១(ឃ) ។

ការ ICTR[11] និងតុលាការ ICTY[12]។ ជាការពិតគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានលើកឡើងថាការធានាចំពោះអនាគតិ *"គឺជាសិទ្ធិដាច់ខាតដែលមិនអាចលើកឡើងឡើយ"*[13]។ ដូចដែលបានសម្រេចដោយតុលាការអឺរ៉ុបសិទ្ធិមនុស្ស: "អ្វីដែលជាការព្រួយបារម្ភនោះ គឺទំនុកចិត្តដែលតុលាការទាំងឡាយនៅក្នុងសង្គមប្រជាធិបតេយ្យត្រូវតែជំរុញឲ្យសាធារណៈជនមានជឿទុកចិត្ត"[14]។ អង្គជំនុំជម្រះនេះបានសម្តែងនូវមនោសញ្ចេតនានេះជាបន្តបន្ទាប់ "ការធានារក្សាឯករាជ្យភាពតុលាការ គឺមានសារៈសំខាន់ជាទីបំផុត និងជាចំណុចស្នូលដល់ទំនុកចិត្តរបស់សាធារណៈនៅក្នុងតុលាការ"[15]។

## ខ. ការដកខ្លួន និង បណ្តឹងជំទាស់ចៅក្រម

6. វិធាន ៣៤ នៃវិធានផ្ទៃក្នុង ដោះស្រាយលើ "ការដកខ្លួន និងការប្តឹងជំទាស់ចៅក្រម" ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖

---

[10] មាត្រា១៧(១) (ធាតុផ្សំទូទៅ) ('ក្នុងការកំណត់បទចោទប្រកាន់ណាមួយ ជនជាប់ចោទត្រូវមានសិទ្ធិទទួលបាន [...] ការជំនុំជម្រះដោយយុត្តិធម៌ និងដោយឥតលម្អៀង [...])។

[11] មាត្រា១៣ ('ចៅក្រមអាសនៈ និងចៅក្រម *បម្រុង* ជាបុគ្គលមានសីលធម៌ខ្ពស់ មិនលម្អៀង និងសុចរិតដែលមានលក្ខណៈសម្បត្តិ ដែលជាលក្ខខណ្ឌតម្រូវនៅក្នុងប្រទេសរៀងៗខ្លួនសម្រាប់ការតែងតាំងជាតំណែងចៅក្រមខ្ពស់បំផុត) ។

[12] មាត្រា១២(១) ('ចៅក្រមអាសនៈ និងចៅក្រមបំរុងត្រូវជាបុគ្គលមានសីលធម៌ខ្ពស់ មិនលម្អៀង និងសុចរិត ដែលមានលក្ខណៈសម្បត្តិតម្រូវនៅក្នុងប្រទេសរៀងៗខ្លួនសម្រាប់ការតែងតាំងជាតំណែងចៅក្រមខ្ពស់បំផុត។')

[13] *រឿងក្តី Gonzalez del Rio តទល់នឹង* Peru, លិខិតឆ្លើយឆ្លងលេខ 263/1987, ឯកសារ អ.ស.ប CCPR/C/46/D/263/1987, ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩២ (គូសបញ្ជាក់បន្ថែម)។

[14] *រឿងក្តី Ferrantelli និង Santangelo តទល់នឹង* Italy, ECtHR App Nos 48/1995 & 554/640, 'សាលក្រម', ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៦ ('សាលក្រម Ferrantelli'), កថាខណ្ឌ៥៨។

[15] ឯកសារ E-5/3 "សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំជំទាស់ចៅក្រម និល ណុន និងសំណើដែលពាក់ព័ន្ធនានា ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ERN 00640427–00640435 (ពាក្យបណ្តឹងជំទាស់ចំពោះចៅក្រម និល ណុន) កថាខណ្ឌ ១១ ។ សូមមើលផងដែរនៅកថាខណ្ឌទី៥ នៃបណ្តឹងជំទាស់ខាងលើ ("សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមួយមិនលម្អៀង និងឯករាជ្យ គឺជាធាតុផ្សំសំខាន់នៃសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌") ។ កថាខណ្ឌទី១១ ("ដូចដែលបានកត់សំគាល់ គោលបំណងរបស់បទប្បញ្ញត្តិស្តីពីការដកចៅក្រម និងជំទាស់ចៅក្រម គឺដើម្បីធានាអនាគតិរបស់ចៅក្រមនៅក្នុងករណីជាក់លាក់") ។ កថាខណ្ឌទី១៤ ("ខណៈជាតុលាការគំរូ តុលាការនេះអាចលើកកំពស់ការធានានូវឯករាជ្យភាព និងសុចរិតភាពរបស់តុលាការ") ។

> ភាគីអាចធ្វើបណ្តឹងជំទាស់ចំពោះសហចៅក្រមស៊ើបអង្កេត ឬ ចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីណាមួយ [...] ដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឲ្យមានភាពលម្អៀង[16]។

ភាគីដាក់ពាក្យប្តឹងជំទាស់ 'ត្រូវបង្ហាញឲ្យច្បាស់លាស់អំពីមូលហេតុនៃការប្តឹងជំទាស់ និងត្រូវមានភស្តុតាងបញ្ជាក់ផងដែរ'[17] និងពាក្យបណ្តឹងត្រូវធ្វើឡើងឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ'[18]។ ពាក្យប្តឹងជំទាស់ប្រឆាំងនឹងចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងបញ្ហាក្នុងអំឡុងពេលជំនុំជម្រះ ត្រូវដាក់ជូន "នៅមុនពេលធ្វើសេចក្តីសម្រេចចុងក្រោយលើសំណុំរឿងនោះ"[19]។ នៅក្នុងករណីបែបនេះបណ្តឹងត្រូវដាក់ប្តឹងឲ្យបានត្រឹមត្រូវនៅអង្គជំនុំជម្រះសាលាដំបូងខ្លួនឯង[20]។ បទបញ្ញត្តិនេះស្របទៅនឹងច្បាប់ជាធរមានរបស់កម្ពុជា ពោលគឺក្រមនីតិវិធីព្រហ្មទណ្ឌ[21]។

---

[16] វិធាន៣៤(២) (គូសបញ្ជាក់បន្ថែម)។

[17] វិធាន៣៤(៣)។

[18] *ដូចជើងទំព័រខាងលើ*។

[19] វិធាន ៣៤(៤)(គ)។

[20] *សូមមើល* វិធាន៣៤(៥) ('ពាក្យបណ្តឹងជំទាស់ចំពោះសហចៅក្រមស៊ើបអង្កេត ត្រូវដាក់ជូនទៅអង្គបុរេជំនុំជម្រះ ។ ក្នុងករណីផ្សេងទៀត ពាក្យបណ្តឹងជំទាស់ត្រូវដាក់ជូនទៅអង្គជំនុំជម្រះណាមួយ ដែលចៅក្រមនោះស្ថិតនៅ ។ [...]។')

[21] សូមមើលឧទាហរណ៍ មាត្រា ៥៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("ភាគីដែលចង់ប្តឹងជំទាស់ចៅក្រមមានអាសនៈណាមួយ ត្រូវតែជូនពាក្យប្តឹងតាំងពីពេលខ្លួនបានដឹងពីមូលហេតុនៃការប្តឹងជំទាស់ បើពុំដូច្នេះទេ មិនអាចទទួលយកបានឡើយ ។ ក្នុងករណីណាក៏ដោយ ពាក្យប្តឹងជំទាស់ចៅក្រមនោះមិនអាចធ្វើបានឡើយ នៅពេលបិទពិភាក្សាដេញដោល ។ មាត្រា ៥៥៨ នៃច្បាប់នេះ ("ភាគីដែលចង់ប្តឹងជំទាស់ចៅក្រមត្រូវតែចង្អុលបង្ហាញឲ្យបានច្បាស់លាស់អំពីមូលហេតុនៃការប្តឹងជំទាស់ ហើយត្រូវមានភស្តុតាងបញ្ជាក់ច្បាស់លាស់ បើមិនដូច្នេះទេពាក្យប្តឹងនេះពុំអាចទទួលយកបានឡើយ ។

7. ការងាកចេញយ៉ាងច្បាស់លាស់ និងមិនសមហេតុផលពីច្បាប់ជាតិ[22] វិធាន៣៤(៥) ចែងថា នៅពេលដាក់បណ្ដឹងជំទាស់នោះហើយ 'ចៅក្រមដែលកំពុងមានបញ្ហាអាចបន្តចូលរួមនៅក្នុងកិច្ច ដំណើរការនីតិវិធី ដោយរង់ចាំសេចក្ដីសម្រេចលើបណ្ដឹងជំទាស់។ ប៉ុន្តែចៅក្រមនោះ[...] *អាចសម្រេចចិត្តលាលែងដោយស្ម័គ្រចិត្តបាន* នៅគ្រប់ពេលវេលាក្នុងដំណើរការនីតិវិធី'[23]។ នេះមិនស្របនឹងមាត្រា ៥៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងថា "ចៅក្រមដែលត្រូវគេប្ដឹងជំទាស់ *ត្រូវដកខ្លួន* ចេញពីការស៊ើបអង្កេត ឬការជំនុំជម្រះ"[24]។ ទោះជាក្នុងករណីណាក៏ដោយ ទាំងវិធានក្នុងនិងក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ចៅក្រមដែលត្រូវប្ដឹង ដែលបានលាលែង បើទោះបីជាដោយស្ម័គ្រចិត្តឬដោយចាប់បង្ខំដោយច្បាប់ក៏ដោយ ក៏"ត្រូវតែបានជំនួស" សម្រាប់គោលបំណងនៃបណ្ដឹងជំទាស់នេះតែប៉ុណ្ណោះ'[25]។

8. នៅពេលអនុវត្តវិធាន ៣៤ នៃវិធានផ្ទៃក្នុងនៅក្នុង អង្គជំនុំជម្រះសាលាដំបូងបានអនុម័តយក ការវាយតម្លៃដែលបង្កើតឡើងជាលើកដំបូងដោយអង្គជំនុំជម្រះតុលាការកំពូលនៅ ICTY នៅ

---

[22] កំណត់សំគាល់៖ មេធាវីការពារក្ដីបានជំទាស់ជាបន្តបន្ទាប់ទៅនឹងការងាកចេញពីនីតិវិធីដែលនៅជាធរមានរបស់កម្ពុជា ដោយការយោងមិនសមហេតុផលទៅលើមាត្រា ១២(១)នៃកិច្ចព្រមព្រៀង អវតក ។ សូមមើលឧទាហរណ៍ ឯកសារ E-51/3 "អញ្ញត្រកម្មរួម" ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ ERN 00648279–00648310 ។ បើតាមមេធាវីការពារក្ដីដឹង មិនមានការផ្ដល់យុត្តិកម្មបែបនេះ តាមវិធាន ៣៤ ទេ ។ មេធាវីការពារក្ដីមិនទទួលយកការបកស្រាយលើចំណុចនេះ ដោយអង្គជំនុំជម្រះឡើយ ។ សូមមើលឯកសារ E-51/14 "សេចក្ដីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ដែលលើកឡើងពីលក្ខណៈគ្មានធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុងរបស់ អវតក" ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ ERN 00707531–00707535 ។ តែដោយសារការសេចក្ដីជំទាស់នេះមិនអាចប្ដឹងឧទ្ធរណ៍ភ្លាមៗបាន នោះមេធាវីការពារក្ដីសូមបញ្ជាក់ឡើងវិញពីការជំទាស់របស់ខ្លួន

[23] វិធាន៣៤(៥) នៃវិធានផ្ទៃក្នុង។

[24] បញ្ជាក់បន្ថែម ។

[25] វិធាន៣៤(៦) នៃវិធានផ្ទៃក្នុង ។ (កត់សំគាល់ថាបើសិនចៅក្រមដែលរងការប្ដឹងជំទាស់លាលែង ចៅក្រមរូបនោះត្រូវតែដាក់ជំនួសនៅក្នុងអង្គជំនុំជម្រះ ដោយចៅក្រមបម្រុងម្នាក់ សម្រាប់គោលបំណងនៃបណ្ដឹងជំទាស់តែប៉ុណ្ណោះ) មាត្រា ៥៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (បង្ហាញថាចៅក្រមដែលរងការប្ដឹងជំទាស់ ត្រូវតែជំនួសដោយចៅក្រមម្នាក់ទៀត ដែលត្រូវតែចាត់តាំងដោយប្រធានតុលាការរបស់ខ្លួន ។

ក្នុងរឿងក្តី Anto Furundžija[26]។ យោងតាមបទដ្ឋាននោះ ចៅក្រមម្នាក់នឹងត្រូវបានគេយល់ឃើញថាមិនមានភាពឯករាជ្យ និងភាពលម្អៀង (ហេតុដូច្នេះ អាចជាកម្មវត្ថុនៃការប្តឹងជំទាស់) បើសិនជាត្រូវគេមើលឃើញថាភាពលម្អៀងជាក់ស្តែងបានកើតឡើង ឬ'មានការលេចឡើងនូវភាពលម្អៀងដែលមិនអាចទទួលយកបាន' ("ការវាយតម្លៃបែបសន្សានុម័ត")[27]។

9. ក្នុងការពិចារណាភាពមិនលម្អៀងជាអត្តនោម័ត អង្គជំនុំជម្រះតុលាការកំពូលនៅ ICTY "បានប្រកាសជាច្រើនដងថា ភាពមិនលម្អៀងជាបុគ្គលរបស់ចៅក្រម ត្រូវតែបានសន្មតជាមុនរហូតទល់តែមានភស្តុតាងផ្ទុយ[28]។ ទាក់ទងនឹងប្រភេទនៃភស្តុតាងតម្រូវ [ដើម្បីជំនះឲ្យបានពីការសន្មតជាមុននៃភាពមិនលម្អៀង] តុលាការ [ECtHR] ក្នុងចំណោមបញ្ហាផ្សេងទៀតបានស្វែងរកឲ្យមានការធានាថា ចៅក្រមម្នាក់បានបង្ហាញអរិភាពឬបំណងមិនល្អ[29]។ កត់សម្គាល់ថា

---

[26] *សូមមើល* 'សេចក្តីសម្រេចលើបណ្តឹងជំទាស់ចំពោះចៅក្រម និល ណុន នៅកថាខណ្ឌទី៦ (លើកមកសំអាងសេចក្តីសម្រេច *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Furundžija*, IT-95-17/1-A, 'សេចក្តីសម្រេច ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ ('សេចក្តីសម្រេច Furundžija') ព្រមទាំងយុត្តិសាស្ត្រលើកមុនៗរបស់ អវតក និងយុត្តិ សាស្ត្រអន្តរជាតិដទៃទៀត ។

[27] សូមមើលឯកសារ **E-55/4** សេចក្តីសម្រេចលើពាក្យប្តឹងជំទាស់របស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី ប្រឆាំងចៅក្រម និល ណុន, ចៅក្រម Silvia Cartwright, ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne, និងចៅក្រម ធូ មរណី ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១១ ERN 00655691–00655700 ។ (អត្ថបទពេញនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង") នៅកថាខណ្ឌ ១១ (យុត្តិសាស្ត្ររបស់ អវតកក និងតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានរកឃើញជាញឹកញាប់ថាលក្ខខណ្ឌតម្រូវនៃភាពមិនលម្អៀង ត្រូវបានរំលោភនៅករណីដែលចៅក្រមលម្អៀងជាក់ស្តែង ។ (លើកមកសំអាងសាលក្រមក្នុងរឿងក្តី Furundžija, កថាខណ្ឌ១៨១-១៨៨) ។ សូមមើលផងដែរឯកសារ E-63/5 សេចក្តីសម្រេចលើសំណើរបស់ អៀង ធីរិទ្ធ និង អៀង សារី សុំប្តឹងជំទាស់ចៅក្រម យូរ ឧត្តារា ពីគណៈកម្មាធិការពិសេស និងសំណើសុំឲ្យមានសវនាការសួរដេញដោលជាសាធារណៈ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ ERN 00686820–00686826 ("សេចក្តីសម្រេចលើពាក្យប្តឹងជំទាស់ចៅក្រម យូរ ឧត្តារា") នៅកថាខណ្ឌទី១១ ។

[28] សាលក្រមក្នុងរឿងក្តី Furundžija, កថាខណ្ឌ១៨២ (សំអាងយុត្តិសាស្ត្ររបស់ ECtHR ), ដូចគ្នា ជើងទំព័រលេខ ២៤៤ (កត់សម្គាល់ថា "មិនមានអ្វីបង្កើតបានជាករណីរំលោភមាត្រា ៦ ក្រោមធាតុផ្សំនៃការវាយតម្លៃនេះ") ។ កត់សម្គាល់: វាមិនមែនជាករណីតទៅទៀតហើយ ។ សូមមើល [...] ខាងក្រោម ។

[29] *រឿងក្តី Kyprianou តទល់នឹង ប្រទេសស៊ីប្រ៍ស* (Cyprus), ECtHR ពាក្យបណ្តឹងលេខ 73797/1 "សេចក្តីសម្រេច" ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ នៅកថាខណ្ឌទី១១៩ ។ សូមមើលផងដែររឿងក្តី *Olujic តទល់នឹង ប្រទេស Latvia* EctHR ពាក្យបណ្តឹងលេខ 22330/05 "សេចក្តីសម្រេច"ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៩ នៅកថាខណ្ឌទី១១ ។

ការលំបាកក្នុងការរកភស្តុតាងពីភាពមិនលម្អៀងជាអត្តនោម័ត តុលាការ ECtHR បានសង្កត់ធ្ងន់លើការការពារបន្ថែមដែលផ្តល់ដោយការវាយតម្លៃជាសត្យានុម័ត ជាជម្រើសមួយផ្សេងទៀតចំពោះការវិភាគជាអត្តនោម័តដែលតឹងរឹង[30]។ ទោះជាក្នុងករណីណាក៏ដោយយុត្តិសាស្ត្រលើកឡើងពីការអនុវត្តការវាយតម្លៃពីរ[31] ដោយផ្អែកលើអង្គហេតុដែលជាបញ្ហា "ពុំមានការចន្លោះប្រហោងក្នុងការបែងចែករវាងសញ្ញាណពីរនេះទេ ដោយសារការប្រព្រឹត្តរបស់ចៅក្រមម្នាក់អាចមិនគ្រាន់ តែមានមន្ទិលសង្ស័យពីភាពមិនលម្អៀង តាមការមើលឃើញរបស់អ្នកអង្កេតការខាងក្រៅ(ការវាយតម្លៃជាអត្តនោម័ត) ប៉ុន្តែថែមទាំងនាំឲ្យមានការជឿពីលក្ខណៈជាបុគ្គលរបស់ចៅក្រមផងដែរ (ការវាយតម្លៃជាអត្តនោម័ត)[32]។

10. ការវាយតម្លៃជាសត្យានុម័ត ត្រូវបានបំពេញក្នុងករណីដែលកាលៈទេសៈដែលនាំឲ្យអ្នកអង្កេតការឥតលម្អៀងដែលទទួលបានព័ត៌មានត្រឹមត្រូវ យល់ឃើញយ៉ាងត្រឹមត្រូវពីការលម្អៀង"[33]។ អ្នកអង្កេតការឥតលម្អៀង ត្រូវតែជា"បុគ្គលម្នាក់ដែលទទួលបានព័ត៌មានគ្រប់គ្រាន់ជាមួយនឹងការយល់ដឹងគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រាប់បញ្ចូលទាំងប្រពៃណីនៃសុចរិតភាព និងភាព

---

[30] *រឿងក្តី* *Kyprianou* នៅកថាខណ្ឌទី១១៩ (បើទោះបីជាមានការលំបាកខ្លះក្នុងការបង្ហាញភស្តុតាងដែលផ្ទុយនឹងការសន្មតជាមុន ក៏គេត្រូវចង់ចាំថាលក្ខខណ្ឌតម្រូវនៃភាពលម្អៀងជាសត្យានុម័តផ្តល់នូវការធានាសំខាន់បន្ថែមទៀត ។ និយាយម្យ៉ាងទៀត តុលាការបានទទួលស្គាល់ការលំបាកក្នុងការរកភស្តុតាងបញ្ជាក់ពីការរំលោភមាត្រា ៦ ស្តីពីភាពលម្អៀងជាអត្តនោម័ត ហើយសម្រាប់មូលហេតុនេះ វាបានលើកឡើងនូវបញ្ហានៃភាពលម្អៀងដែលសំដៅលើការវាយតម្លៃជាសត្យានុម័ត ។ សូមមើលផងដែររឿងក្តី *Olujic* នៅកថាខណ្ឌ ១១ ។

[31] សូមមើល *រឿងក្តី* *Kyprianou* នៅកថាខណ្ឌទី១២០ (សំអាងករណី *Busce* *និង* *lavents* (ហេតុដូច្នេះក្នុងករណីដែលប្រធានតុលាការសម្តែងមតិជាសាធារណៈដែលនាំគេយល់ឃើញថាគាត់បានបង្កើតរួចមកហើយនូវទស្សនៈមិនពេញចិត្តចំពោះភាគីប្តឹងនៅមុនការដឹកនាំសវនាការដែលគាត់នឹងសម្រេចលើករណីនេះ ហេតុដូចនេះសេចក្តីថ្លែងរបស់គាត់ជាមូលហេតុដែលនាំឲ្យជនសង្ស័យព្រួយបារម្ភពីភាពលម្អៀងរបស់គាត់ ។ និយាយម្យ៉ាងទៀត បើចៅក្រមបានចូលរួមការរិះគុណជាសាធារណៈទៅលើជនជាប់ចោទ និងបានសម្តែងការភ្ញាក់ផ្អើលជាសាធារណៈថាជនជាប់ចោទមិនបានសារភាព តុលាការសម្រេចបញ្ហាដោយឈរលើការវិភាគជាសត្យានុម័ត ។ សូមមើលផងដែររឿងក្តី *Olujic* នៅកថាខណ្ឌ ១២ ។

[32] សូមមើល *រឿងក្តី* *Kyprianou* នៅកថាខណ្ឌទី១១៩ ។ រឿងក្តី *Olujic* នៅកថាខណ្ឌ ១១ ។

[33] សូមមើលអត្ថបទពេញនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅកថាខណ្ឌទី១១ (បានលើកសំអាងសេចក្តីសម្រេចក្នុងរឿងក្តី Furundžija, កថាខណ្ឌ១៨៩) ។ សូមមើលសេចក្តីសម្រេចលើពាក្យប្តឹងជំទាស់ចៅក្រម យូរ ឧត្តរា នៅកថាខណ្ឌទី១១ ។

មិនលម្អៀង ដែលបង្កើតបានជាផ្នែកមួយនៃសាវតារ និងអង្គហេតុដែលថាភាពមិនលម្អៀងគឺជាករណីយកិច្ចមួយក្នុងចំណោមករណីកិច្ចផ្សេងៗដែលចៅក្រមគ្រប់រូបត្រូវតែប្រកាន់ភ្ជាប់"[34]។ ម្យ៉ាងវិញទៀត ដូចបានបញ្ជាក់ដោយអង្គជំនុំជម្រះពិសេសនៃតុលាការ ICTY៖ "អង្គជំនុំជម្រះត្រូវតែសម្រេចថា តើការយល់ឃើញរបស់អ្នកអង្កេតការដែលមិនលម្អៀងជាមួយនឹងការយល់ដឹងគ្រប់គ្រាន់លើកាលៈទេសៈនានាដើម្បីធ្វើការវិនិច្ឆ័យដោយសមហេតុផលថា [ចៅក្រមដែលរងនូវការប្តឹងជំទាស់] នឹងមិនអាចធ្វើការវិនិច្ឆ័យដោយអនាគតិលើបញ្ហាទាំងឡាយដែលលេចចេញពីរឿងក្តីដែរ ឬទេ"[35]។

11. ភាគីដែលដាក់បណ្តឹងជំទាស់មានបន្ទុកបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ ដែលអាចជឿថាចៅក្រមដែលរងការប្តឹងជំទាស់ មិនលម្អៀងជាអត្តនោម័ត ឬសត្យានុម័ត (អាចជាករណីនេះ)[36]។ ទាំងវិធានផ្ទៃក្នុងឬក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនមានចែងពីការធ្វើសវនាការដេញដោលផ្ទាល់មាត់លើពាក្យប្តឹងជំទាស់ "តម្លាភាពនៃដំណើរការនីតិវិធីនឹងត្រូវបានធានានាដោយ [...] ចំណាត់ថ្នាក់នៃការដាក់ឯកសារទាំងអស់ទាក់ទងនឹង [ពាក្យប្តឹងជំទាស់ទាំងអស់] ជាឯកសារសាធារណៈ"[37]។

## គ. សេចក្តីថ្លែងការណ៍ដោយចៅក្រមក្នុងតំណែងទៅកាន់សារព័ត៌មាន

---

[34] អត្ថបទពេញនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅកថាខណ្ឌទី១១ (បានលើកសំអាងសេចក្តីសម្រេចក្នុងរឿងក្តី Furundžija, កថាខណ្ឌ១៩០) ។ សូមមើលផងដែរសេចក្តីសម្រេចលើពាក្យប្តឹងជំទាស់ចៅក្រម យូរ ឧត្តរា នៅកថាខណ្ឌទី១១ ។

[35] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić*, IT-95-05/18-PT, 'សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Picard និងរបាយការណ៍ជូនអនុប្រធានតុលាការអនុលោមតាមវិធាន ១៥(ខ)(ii)' ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩ ('សេចក្តីសម្រេចក្នុងរឿងក្តី Karadžić'), កថាខណ្ឌ១៨ (ការទាញហេតុសំអាងខាងក្នុងត្រូវបានលុប)។

[36] សេចក្តីសម្រេចក្នុងរឿងក្តី Furundžija, កថាខណ្ឌ១៩៦ ។

[37] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចំពោះចៅក្រម និល ណុន នៅកថាខណ្ឌទី៣ ។ សូមមើលផងដែរអត្ថបទពេញនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅកថាខណ្ឌទី៨ ។

12. ក្នុងទសវត្សរ៍កន្លងទៅនេះ តុលាការ ECtHR បានបង្កើតយុត្តិសាស្ត្រជាបន្តបន្ទាប់ទាក់ទងនឹងការចេញសេចក្តីប្រកាសព័ត៌មានដែលធ្វើឡើងដោយចៅក្រមក្នុងតំណែង នៅមុនការបញ្ចប់ការជំនុំជម្រះ។ បញ្ហានេះមានកើតនៅក្នុងរឿងក្តី *(Buscemi តទល់ប្រទេសអ៊ីតាលី)* តុលាការ ECtHR ដែលយល់ឃើញដូចខាងក្រោម:

> លើសពីនេះអាជ្ញាធរតុលាការត្រូវអនុវត្តឆន្ទានុសិទ្ធិជាអប្បបរិមា ទាក់ទងនឹងករណីដែលពួកគេកំពុងដោះស្រាយ ដើម្បីរក្សាឋានៈរបស់ពួកគេជាចៅក្រមមិនលម្អៀង។ ឆន្ទានុសិទ្ធិនោះមិនលើកទឹកចិត្តឲ្យពួកគេប្រើប្រាស់សារព័ត៌មានដើម្បីទាញយកប្រយោជន៍នោះទេ [...] ។ វាជាការទាមទារខាងយុត្តិធម៌និងការិយាល័យតុលាការដែលពាក់ព័ន្ធដែលដាក់ភារកិច្ចនោះ[38]។

ជាពិសេសតុលាការ ECtHR បានរកឃើញថាក្នុងករណីដែលចៅក្រមក្នុងតំណែង "សម្តែងជាសារណៈដែលនាំឲ្យគេយល់ឃើញថា គាត់បានបង្កើតរួចមកហើយនូវទស្សនៈមិនពេញចិត្តករណីរបស់ចុងចោទ" ចំណុចនេះអាចមានវិសមិតភាពជាមួយភាពមិនលម្អៀងដែលតម្រូវដោយតុលាការណាមួយអនុលោមតាមមាត្រា៦(១) នៃអនុសញ្ញាអឺរ៉ុប[39]។ នៅក្នុងរឿងក្តី *Buscemi* តុលាការសន្និដ្ឋានថា-ក្នុងករណីដែលប្រធានតុលាការដែលកំពុងតែសម្រេចលើករណីរបស់ម្ចាស់បណ្តឹង បានធ្វើសេចក្តីថ្លែងការណ៍ដល់សារព័ត៌មានដោយលើកឡើងថាអ្នកដាក់ពាក្យប្តឹងផ្តល់ភស្តុតាងមិនត្រឹមត្រូវ[40] ដូច្នេះការកត់សម្គាល់បែបនេះ "ជាការធ្វើយុត្តិកម្មជាសត្យានុម័តចំពោះការព្រួយបារម្ភណ៍របស់ម្ចាស់បណ្តឹងពីអនាគតិរបស់ចៅក្រម[41] ។

13. បីឆ្នាំកន្លះក្រោយមកតុលាការ ECtHR ទទួលស្គាល់ពីការរំលោភមាត្រា៦(១) ក្រោមការវាយតម្លៃជាអត្តនោម័តនៃការលុបចោលភាពស្រដៀងផ្នែកអង្គហេតុ។ ក្នុងរឿងក្តី *Lavents តទល់*

---

[38] *រឿងក្តី* *Buscemi* តទល់ប្រទេសអ៊ីតាលី, ECtHR ពាក្យបណ្តឹងលេខ 29569 "សេចក្តីសម្រេច" ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ១៩៩៩ នៅកថាខណ្ឌទី ៦៧ (បញ្ជាក់បន្ថែម) ។ សូមមើលផងដែរ *រឿងក្តី Kyprianou* នៅកថាខណ្ឌទី១២០ (សំអាងរឿងក្តី Buscemi) រឿងក្តី *Olujic* នៅកថាខណ្ឌ ១២ ។

[39] *រឿងក្តី Buscemi* នៅកថាខណ្ឌ ៦៨ ។ កំណត់សំគាល់មាត្រា ៦(១) របស់ ECtHR ដូចគ្នានឹង [...] ដែល [...] ។

[40] *រឿងក្តី Buscemi* នៅកថាខណ្ឌ [...] ។

[41] *រឿងក្តី Buscemi* នៅកថាខណ្ឌ ៦៨ ។

*ប្រទេសឡាតវី*[42] អ្នកដាក់ពាក្យសុំបានដាក់សំណើជាច្រើនតែមិនបានជ័យជំនះ ក្នុងការសុំប្តឹងជំទាស់ចៅក្រមក្នុងអំឡុងពេលដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងរូបគាត់- សំណើមួយប្រឆាំងនឹងតុលាការទាំងមូល និងសំណើចំនួនពីរប្រឆាំងនឹងប្រធានចៅក្រម ដែលសំណើនីមួយៗចោទពីភាពលម្អៀង[43]។ ភ្លាមៗបន្ទាប់ពីដាក់សំណើលើកទីពីរប្រឆាំងនឹងប្រធានចៅក្រម ករណីទីពីរទាក់ទងនឹងការរិះគន់ជាសាធារណៈមកលើមេធាវីការពារក្តីតាមរយៈសេចក្តីប្រកាសព័ត៌មាន Latvian[44] ដែលរួមមានទាំងការទាយទុកជាមុននូវលទ្ធផលនៃសំណុំរឿង។ បើពិចារណាពីបទដ្ឋានទូទៅមានក្នុងករណី *Buscemi* ដែលតុលាការបានបង្ហាញយ៉ាងច្បាស់ពីការមិនគម្បីក្នុងការប្រើប្រាស់ប្រព័ន្ធសារព័ត៌មានដើម្បីបញ្ជាក់ពីទស្សនៈអវិជ្ជមានទៅលើយុទ្ធសាស្ត្រមេធាវីការពារក្តី[45]។ ហើយច្បាស់បំផុតនោះ គឺគោលជំហរដែលបានលើកឡើងដោយប្រធានចៅក្រមអំពីលទ្ធផលរបស់សំណុំរឿង គឺគួរឲ្យតក់ស្លុតបំផុតនៅក្នុង ECtHR[46] ត្រូវបានកំណត់ថាសេចក្តីថ្លែងការជាសាធារណៈបង្កើតបានជាការរិះគន់ដោយមិនសមស្របលើ "*ការប្រព្រឹត្តរបស់មេធាវីការពារក្តីនៅចំពោះមុខតុលាការ*[47]"។

---

[42] *រឿងក្តី Lavents តទល់ប្រទេសឡាតវី,* ECtHR ពាក្យសុំលេខ 58442/00 "សេចក្តីសម្រេច" ចុះថ្ងៃទី ២៨ ខែកុម្ភៈឆ្នាំ ២០០៣ ។

[43] *រឿងក្តី Lavents* នៅកថាខណ្ឌ ២៨-២៩ ។

[44] *រឿងក្តី Lavents* នៅកថាខណ្ឌ ៣០។ មេធាវីរបស់ Lavents គេងយកផលប្រយោជន៍ពីការប្តឹងជំទាស់ខ្ញុំ ។ ខ្ញុំមិនយល់ថាមូលហេតុអ្វី [...] នោះទេ ។ វាពិតជាមិនអាចពិចារណាករណីនេះតទៅទៀតទេ ។ [...] ប្រសិន បើមេធាវីរបស់ Lavents និងជនជាប់ចោទពិតជាមានផលប្រយោជន៍ក្នុងការពន្លឿនការពិចារណាករណីនេះមែន ករណីត្រូវបញ្ចប់ក្នុងរយៈពេលប្រាំមួយខែ ឬប្រាំពីរខែ ។ វាអាចធ្វើ បានបើសិនពួកគេមិនដកខ្ញុំចេញពីករណីនេះ[...] ។ ក្រៅពីនេះពួកគេជាមនុស្សឆ្លាតណាស់ ពួកគេអាចពិភាក្សាភស្តុតាងនៅក្នុងសំណុំរឿង [...] ។ ប៉ុន្តែមេធាវីសម្រេចម្តេចខ្ញុំតាមមធ្យោបាយណាមួយ និងសំណើសុំដកខ្ញុំចេញពីករណី ត្រូវបានរឹតបណ្តឹងម្តងមួយ ម្តងមួយ [...]

[45] សូមមើល Lavent កថាខណ្ឌទី១១៨។ពិសេស ប្រធាន និងសមាជិកណាមួយរបស់តុលាការដែលសម្រេចលើករណី បានសម្តែង ជាសាធារណៈ ដោយបានបង្កប់ន័យក្នុងការវាយតម្លៃជាអវិជ្ជមាននៃបុព្វហេតុរបស់ភាគី គឺមានវិសមិតភាពជាមួយលក្ខខណ្ឌតម្រូវនៃអនាគតិរបស់ចៅក្រម[..]

[46] សូមមើល *Lavents* កថាខណ្ឌ ១១៨។

[47] *រឿងក្តី Lavents* នៅកថាខណ្ឌ១១៩ ។ (អត្ថបទបកប្រែក្រៅផ្លូវការ) កត់សំគាល់: អត្ថបទដើមជាភាសាបារាំងមានន័យថា ('l'attitude de la défense devant le tribunal')

ដោយគាំទ្រដល់ការទាមទាររបស់ Lavents តុលាការសន្និដ្ឋានថា ការប្រព្រឹត្តរបស់ប្រធានចៅក្រម "ទោះជាក្រោមកាលៈទេសៈណាក៏ដោយ ក៏មិនអាចត្រូវបានពិចារណាថាស្របគ្នាជាមួយលក្ខខណ្ឌតម្រូវនៃមាត្រា៦(១) នៃអនុសញ្ញាអឺរ៉ុបដែរ ហើយហេតុដូច្នេះម្ចាស់សំណើមានមូលហេតុរឹងមាំចំពោះការព្រួយបារម្ភពីកង្វះអនាគតិរបស់ចៅក្រម"[48]។

14. នៅពេលថ្មីៗនេះ ការអនុវត្តការវាយតម្លៃជាសត្យានុម័តនៅក្នុងរឿងក្ដីសំខាន់មួយទៀត (*Olujic តទល់នឹងប្រទេស Lavia*[49]) តុលាការ ECtHR យល់ឃើញថាមានការរំលោភមាត្រា៦(១) ក្នុងករណីដែលសមាជិកពរូបនៃក្រុមប្រឹក្សាតុលាការ ដែលជំនុំជម្រះរឿងក្ដីរបស់អ្នកដាក់ពាក្យបណ្ដឹង បានធ្វើបទអត្ថាធិប្បាយអវិជ្ជមានទៅកាន់ប្រព័ន្ធផ្សព្វផ្សាយទាក់ទងទៅនឹងការការពារក្ដី[50]។ ជាពិសេស ប្រធានចៅក្រមជំនុំជម្រះបានលើកឡើងថា "ការចោទប្រកាន់របស់មេធាវីការពារក្ដីដែល ថារឿងក្ដីនេះមានហេតុផលនយោបាយ មិនមែនជាការពិត"[51]។ ចៅក្រមម្នាក់ក្នុងចំណោមចៅក្រមដទៃទៀតនៅក្នុងក្រុមប្រឹក្សានោះ បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយថាលោក "ចាត់ទុកអ្នកប្ដឹងនិងសេចក្ដីថ្លែងរបស់គាត់អំពីការខ្វះឯករាជ្យភាពរបស់ចៅក្រមថាជារឿងកំប្លែង[52]"។ ជាថ្មីម្ដងទៀត ការលើកមកសំអាងការហាមឃាត់ជាទូទៅក្នុងរឿងក្ដី *Buscemi* ប្រឆាំងនឹងការអធិប្បាយជាវិជ្ជមានលើរឿងក្ដីរបស់ជនជាប់ចោទដែលមិនទាន់សម្រេច តុលាការលើកឡើងថាសេចក្ដីថ្លែងការណ៍ដែលធ្វើឡើងដោយចៅក្រមបីនាក់ជាសាធារណៈបែបនេះ បានបង្កើតឱ្យមាន (i) "មន្ទិលសង្ស័យស្របច្បាប់ទាក់ទងនឹង [...] អនាគតិ"[53] (ii) វាត្រូវធ្វើជា

---

[48] ដូចខាងលើ (អត្ថបទបកប្រែក្រៅផ្លូវការ) កត់សំគាល់: អត្ថបទដើមជាភាសាបារាំងមានន័យថា ('ne peuvent en aucun cas être considérées comme compatibles avec les exigences de l'article 6 § 1 de la Convention. Le requérant avait donc les plus fortes raisons de craindre le manque d'impartialité de cette juge'.

[49] រឿងក្ដី *Olujic តទល់នឹងប្រទេស Lavia បណ្ដឹងរបស់ ECHR No22330/05,* សេចក្ដីសម្រេច ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២00៩។

[50] *រឿងក្ដី Olujic, កថាខណ្ឌទី១៥ ដល់២0។*

[51] *រឿងក្ដី Olujic, កថាខណ្ឌទី១៧។*

[52] *រឿងក្ដី Olujic, កថាខណ្ឌទី១៩ ។*

[53] *រឿងក្ដី Olujic, កថាខណ្ឌទី១៦ ។*

យុត្តិកម្មជាសត្យានុម័តថាជាការព្រួយបារម្ភរបស់អ្នកប្ដឹងពីអនាគតិរបស់ចៅក្រម[54] និង (iii) "បង្ហាញយ៉ាងច្បាស់ [...] ពីភាពលម្អៀងប្រឆាំងនឹងអ្នកប្ដឹង[55]។ ដូច្នេះគេយល់ឃើញថា ការចូលរួមរបស់ចៅក្រមរូបនេះបន្តទៀតទៅក្នុងដំណើរការនីតិវិធី មិនមាន វិសមិតភាពជាមួយលក្ខណ្ឌតម្រូវនៃអនាគតិក្រោមមាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុបឡើយ[56]។

15. ចុងបញ្ចប់ ទាក់ទងនឹងភាពខុសគ្នារវាងភាពលម្អៀង "ជាលក្ខណៈបុគ្គល" និងភាពលម្អៀងទាក់ទងនឹង "មុខងារ" ភាពលម្អៀងជាលក្ខណៈបុគ្គលត្រូវបានអនុវត្តក្នុងរឿងក្ដីនេះ។ ECtHR បានលើកឡើងថា៖

> ភាពលម្អៀងទី២គឺមានចរិតលក្ខណៈជាបុគ្គល និង*កើតចេញពីការប្រព្រឹត្តរបស់ចៅក្រមក្នុងរឿងក្ដីដែលបានលើកឡើងនេះ*។ ផ្អែកលើការវាយតម្លៃជាសត្យានុម័ត ការប្រព្រឹត្តបែបនេះ គឺមានលក្ខណៈគ្រប់គ្រាន់ល្មមអាចធ្វើឲ្យមានការបារម្ភដ៏ត្រឹមត្រូវ និងមានហេតុផលជាសត្យានុម័តដូចក្នុងរឿងក្ដី *Buscemi* ប៉ុន្តែវាក៏អាចមានលក្ខណៈដែលត្រូវលើកឡើងពីបញ្ហាក្រោមការវាយតម្លៃជាអត្តនោម័តផងដែរ (សូមមើលឧទាហរណ៍រឿងក្ដី *Lavents* ) ហើយបង្ហាញពីភាពលម្អៀងជាលក្ខណៈបុគ្គល[57]។

ដូចដែលបានកត់សម្គាល់ពីខាងលើ "ថាតើករណីមួយត្រូវដោះស្រាយតាមការវាយតម្លៃមួយ ឬការវាយតម្លៃមួយទៀត ឬទាំងពីរ វាអាស្រ័យលើអង្គហេតុជាក់លាក់នៃការប្រព្រឹត្តដែលរងការ

---

[54] *រឿងក្ដី Olujic, កថាខណ្ឌទី១៨ (ដងស្រង់ Buscemi)* ។

[55] *រឿងក្ដី Olujic, កថាខណ្ឌទី១៩*។

[56] *រឿងក្ដី Olujic, កថាខណ្ឌទី១៩*។

[57] រឿងក្ដី *Kyprianou*,នៅកថាខណ្ឌ១២១ (បញ្ជាក់បន្ថែម) ។ សូមមើកផងដែរ រឿងក្ដី *Olujic* នៅកថាខណ្ឌទី ១៣ ។ កត់សំគាល់: ទីមួយគឺចរិតលក្ខណៈផ្អែកមុខងារ: ក្នុងករណីដែលកាប្រព្រឹត្តផ្ទាល់ខ្លួនរបស់ចៅក្រមម្នាក់មិនត្រូវបានគេជំទាស់ ប៉ុន្តែឧទាហរណ៍ក្នុងករណីការអនុវត្តតួនាទីផ្សេងៗនៅក្នុងនីតិវិធីតុលាការដោយបុគ្គលតែមួយឬ មានទំនាក់ទំនងជាមួយសកម្មភាពផ្សេងៗទៀតនៅក្នុងនីតិវិធីតុលាការ ជាយុត្តិកម្មជាសត្យានុម័តពីការយល់ច្រឡំនៃអនាគតិរបស់តុលាការ ហើយហេតុដូច្នេះ វាមិនអាចបំពេញបាន ការវាយតម្លៃអត្តនោម័តឡើយ" ។ ដូចខាងលើ ។

ជំទាស់[58]។

## IV. អំណះអំណាង

### ក. សំណើធ្វើឡើងទាន់ពេលវេលា និងអាចទទួលយកបាន

16. ដូចដែលបានតម្រូវដោយវិធាន ៣៤(៣) ពាក្យប្តឹងជំទាស់ហេតុដែលជំទាស់ "បញ្ជាក់យ៉ាងច្បាស់អំពីមូលហេតុនៃការប្តឹងជំទាស់ និងផ្តល់នូវភស្តុតាងគាំទ្រ"។ ពាក្យប្តឹងជំទាស់នេះត្រូវបានដាក់យ៉ាងយកចិត្តទុកដាក់[59] ទៅអង្គជំនុំជម្រះសាលាដំបូង[60]ភ្លាមៗបន្ទាប់ពីមេធាវីការពារក្តីបានដឹងពីមូលហេតុដែលពាក់ព័ន្ធ[61]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងគួរតែទទួលយកពាក្យប្តឹងជំទាស់នេះ ។

### ខ. ចៅក្រម Cartwright ត្រូវតែ(ឬគួរតែ) លាឈប់ ដោយរង់ចាំសេចក្តីសម្រេចលើពាក្យប្តឹងជំទាស់នេះសិន

17. អនុលោមតាមវិធាន ៥៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រម Cartwright ត្រូវតែចុះចេញពីតំណែងដោយរង់ចាំសេចក្តីសម្រេចលើពាក្យសុំជំទាស់បន្ទាន់នេះសិន[62]។ ប្រសិនបើចៅក្រម Cartwright និងអង្គជំនុំជម្រះសាលាដំបូងនៅតែបន្តមិនគោរពនីតិវិធីដែលនៅជាធរមានរបស់ប្រទេសកម្ពុជា នោះយ៉ាងហោចណាស់ចៅក្រម Cartwright គួរតែលាឈប់ពីមុខតំណែងសិនស្របតាមវិធាន ៣៤(៥)។ ទោះជាក្នុងករណីណាក៏ដោយ ចៅក្រម Cartwright ត្រូវតែបាន

[58] រឿងក្តី *Kyprianou*, នៅកថាខណ្ឌ១២១ (បញ្ជាក់បន្ថែម) ។

[59] វិធាន៣៤(៤)(គ) (បណ្តឹងជំទាស់ប្រឆាំងចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង, [...]...ទាក់ទងនឹងបញ្ហាដែលបានកើតឡើងក្នុង អំឡុងពេលជំនុំជម្រះ ត្រូវតែដាក់ជូន "មុនពេលធ្វើសេចក្តីសម្រេចចុងក្រោយលើសំណុំរឿងនេះ"។

[60] សូមមើលវិធាន៣៤ (៥) (បណ្តឹងជំទាស់ចំពោះសហចៅក្រមស៊ើបអង្កេតត្រូវតែដាក់ជូនទៅអង្គបុរេជំនុំជម្រះ។ ក្នុងករណីផ្សេងទៀតពាក្យបណ្តឹងជំទាស់ត្រូវដាក់ជូនទៅអង្គជំនុំជម្រះណាមួយដែលចៅក្រមនោះស្ថិតនៅ)។

[61] វិធាន៣៤(៣)។

[62] សូមមើលកថាខណ្ឌទី៥, ដូចគ្នា។

ដាក់ជំនួសដោយចៅក្រម Fenz ដោយសារតែគោលបំណងនៃបណ្តឹងជិតចិត្តនេះ[63]។

## គ. ដោយសារតែការអត្ថាធិប្បាយរបស់ចៅក្រម Cartwright មិនស្របគ្នាទៅនឹងលក្ខខណ្ឌតម្រូវនៃអនាគតិ គាត់គួរតែត្រូវបានគេហាមឃាត់មិនឲ្យចូលរួមដំណើរការនីតិវិធីបន្តទៀតក្នុងសំណុំរឿង ០០២

### ១.ការថ្លែងរបស់ចៅក្រម Cartwright ទៅកាន់ប្រព័ន្ធផ្សព្វផ្សាយបង្ហាញពីភាពលម្អៀងជាក់ស្តែងប្រឆាំងនឹងមេធាវីការពារក្តី

18. ដូចចៅក្រមទាំងអស់នៅអង្គជំនុំជម្រះសាលាដំបូងដែរ លោកស្រីចៅក្រម Cartwright ទទួលបានការសន្មតទុកជាមុនតាមផ្លូវច្បាប់អំពីអនាគតិ[64] ការថ្លែងផ្ទាល់ខ្លួនដែលមានលក្ខណៈបង្ខូចបង្អាប់[65]ទៅកាន់ប្រព័ន្ធផ្សព្វផ្សាយញូហ្សេឡែនទាក់ទងទៅនឹង"យុត្តិសាស្ត្ររួម" ដែលអនុវត្តដោយមេធាវីការពារក្តី[66] ជាតឹកតាងផ្ទុយទៅនឹងការសន្មតទុកជាមុនអំពីអនាគតិនៅក្នុងរឿងក្តីនេះ[67]។ តាមរយៈពាក្យសំដីនៅពេលថ្មីៗនេះរបស់គាត់ទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ ចៅក្រម Cartwright បានបង្ហាញពីអរិភាព និងបំណងមិនល្អចំពោះវិធីសាស្ត្ររបស់មេធាវីការពារក្តីចំពោះរឿងក្តីនេះ[68] ហើយគាត់បានបង្ហាញពីជំនឿផ្ទាល់ខ្លួនដែលប្រឆាំងយ៉ាងមុតមាំទៅនឹង

---

[63] វិធាន៣៤(៦) (គួរកត់សម្គាល់ផងដែរថាប្រសិនបើចៅក្រមដែលកំពុងមានបញ្ហានោះ សម្រេចចិត្តលាឈប់ពីមុខតំណែង, ចៅក្រមនោះ អាចត្រូវជំនួសដោយចៅក្រមបម្រុងនៃអង្គជំនុំជម្រះនោះបានសម្រាប់តែករណីបណ្តឹងជិតចិត្តនោះប៉ុណ្ណោះ)។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា៥៥៩ (ក្នុងករណីបន្ទាន់ចៅក្រមនោះត្រូវបានជំនួសដោយចៅក្រមម្នាក់ទៀតដែលត្រូវចាត់តាំង ដោយប្រធានតុលាការរបស់ខ្លួន)។

[64] សូមមើលកថាខណ្ឌ ៩ ខាងលើ ។

[65] សម្គាល់៖ នេះពិតជាករណីនៃភាពលម្អៀងជាលក្ខណៈបុគ្គល ទល់នឹងភាពលម្អៀងផ្នែកមុខងារ។ សូមមើលកថាខណ្ឌទី ១៥ ខាងលើ។

[66] សូមមើល កថាខណ្ឌទី២ ខាងលើ។

[67] សូមមើលកថាខណ្ឌ ៩ ខាងលើ ។

[68] ដូចខាងលើ ។

របៀបរបបដែលមេធាវីការពារក្តីបានបង្ហាញតាំងពីមុនមកនៅក្នុងតុលាការ[69]។ ដូចគ្នាទៅនឹងចៅក្រមដែលបានប្រព្រឹត្តខុសនៅក្នុងរឿងក្តី *Buscemi* និង *Lavents* ចៅក្រម Cartwright បានរិះគន់ជាសាធារណៈ "ពីការប្រព្រឹត្តរបស់មេធាវីការពារក្តីនៅចំពោះមុខតុលាការ"[70] ហើយដូចគ្នាទៅនឹងភាគីដែលរងការរំលោភក្នុងរឿងក្តីទាំងនេះ លោក នួន ជា មានហេតុផលគ្រប់គ្រាន់ដែលត្រូវបារម្ភអំពីការខ្វះអនាគតិរបស់ចៅក្រម Cartwright"[71]។

19. វាស្តែងឲ្យឃើញយ៉ាងច្បាស់ពីការថ្លែងជាសាធារណៈរបស់គាត់ដែលចៅក្រម Cartwright ចាត់ទុក មេធាវីការពារក្តីរំខានជាជាងការតំណាងឲ្យកូនក្តីនៅ អវតក[72]។ បទអធិប្បាយ និងការស្នើឡើងដោយអវិជ្ជមានដូចនេះ គឺគ្រប់គ្រាន់ណាស់ទៅហើយក្នុងការយល់ដឹងឃើញអំពីភាពលម្អៀងរបស់ចៅក្រម Cartwright ដោយអនុលោមតាមតេសដែលមានក្នុងករណី *Buscemi* ដែលហាមឃាត់ការប្រើប្រាស់ "ការលើកឡើងជាសាធារណៈដែលថាចៅក្រមបានបង្ហាញនូវការមិនគាំទ្រនូវករណីរបស់ខាងចុងចោទ"[73]។ បញ្ហាដូចគ្នានេះគឺថាការលើកឡើងរបស់ចៅក្រម Cartwright បង្ហាញថា បណ្តឹងជំទាស់លើកមុនរបស់មេធាវីការពារក្តីមិនមានមូលដ្ឋាន និងធ្វើឲ្យប៉ះពាល់ដល់គាត់ជាបុគ្គល និង/ឬដំណើរការនីតិវិធីជាទូទៅ[74]។ ការលើកឡើងបែបនេះ *(a fortior)* ដែលបានធ្វើឡើងនៅក្នុងការអត្ថាធិប្បាយកាលពីលើកមុន បង្កើតបានជាការរំលោភជាអត្តនោម័តទៅលើសេចក្តីសម្រេច *Buscemi*។

20. តែអ្វីដែលនាំឲ្យខាតបង់ខ្លាំងបំផុតនោះ គឺការលើកឡើងដែលថាការលើកពីបញ្ហាជ្រៀតជ្រែកតុលាការ និង/ឬឯករាជភាពតុលាការ (ដូចដែលមេធាវីការពារក្តីបានធ្វើជាបន្តបន្ទាប់មកចាប់

---

[69] ដូចខាងលើ ។

[70] ដូចខាងលើ ។

[71] ដូចខាងលើ ។

[72] សូមមើលកថាខណ្ឌ ២ ខាងលើ (មេធាវីការពារក្តីផ្តោតតែការរខាន ជាជាងតំណាងឲ្យកូនក្តីរបស់ពួកគេ" ។ ចៅក្រម Cartwright និយាយ ។

[73] សូមមើលកថាខណ្ឌ ១២ ខាងលើ។

[74] សូមមើលកថាខណ្ឌ ២ ខាងលើ ("វាជាយុទ្ធសាស្ត្ររួមរបស់មេធាវីការពារក្តី ។ មានពាក្យបណ្តឹងប្រឆាំងនឹងខ្ញុំពីរដង ម្តងជាសមាជិកនៃតុលាការទាំងមូល និងម្តងនោះប្រឆាំងនឹងខ្ញុំជាបុគ្គល ហើយក៏មានបណ្តឹងប្រឆាំងនឹងប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលជាចៅក្រមកម្ពុជា និងចៅក្រមកម្ពុជាដទៃទៀត ។

តាំងពីដើមដំបូងសំណុំរឿង) មេធាវីការពារក្តីកំពុងតែធ្វើសកម្មភាពប្រឆាំងនឹងផលប្រយោជន៍ នួន ជា[75] នេះចាត់ទុកថា ជាការប្រមាថមួយទៀតទៅលើយុទ្ធសាស្ត្រស្របច្បាប់របស់មេធាវីការពារក្តី។ ការលើកឡើងគឺតាមរយៈការអត្ថាធិប្បាយទៅកាន់សារព័ត៌មាននៅថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១២[76] នៅពេលអាន (ដែលការអត្ថាធិប្បាយត្រូវតែ) កើតឡើងដោយសារការថ្លែងនៅប្រាំថ្ងៃមុននោះ[77] ដោយលោកស្រីចៅក្រមលើកឡើងថា (i) ការជំទាស់តវ៉ានេះ គឺពុំមានមូលដ្ឋានផ្លូវច្បាប់ និង/ឬ ឥតប្រយោជន៍ (ii) (ពុំមានការជ្រៀតជ្រែកដែលធ្វើឲ្យប៉ះពាល់ហួសហេតុដល់សំណុំរឿង ០០២ ពីសំណាក់រដ្ឋាភិបាលក្នុងអវតក និង/ឬ (iii) ចៅក្រមទាំងអស់នៃតុលាការនេះរួចផុតពីសំពាធខាងក្រៅ ។ ហេតុដូច្នេះ ទស្សនៈនេះផ្ទុយពីទស្សនៈយល់ឃើញរបស់មេធាវីការពារក្តី ហើយវានៅតែបញ្ហាសម្រាប់ការពិភាក្សាជាចំហនៅក្នុងសំណុំរឿង០០២[78]។ ទាក់ទងនឹងចំណុចនេះ ចៅក្រម Cartwright ទប់ស្កាត់ជាមុន នូវការលើកអំណះអំណាងផ្នែកច្បាប់បន្ថែមទៀតលើបញ្ហាដ៏សំខាន់នេះ។ នេះបង្ហាញជាថ្មីម្តងទៀតពីភាពលម្អៀងរបស់លោកស្រីចៅក្រម[79]។

21. សម្រាប់មូលហេតុទាំងនេះ អនុលោមតាមរឿងក្តី Buscemi ការថ្លែងជាសាធារណៈរបស់ចៅក្រម Cartwright បង្ហាញយ៉ាងច្បាស់ពីទស្សនៈមិនពេញចិត្តករណី នួន ជា[80]។ ដូចដែលតុលាការ ECtHR បានយល់ឃើញរួចមកហើយ ការលម្អៀងជាអត្តនោម័តខាងបុគ្គលនេះ “មិនអាចពិចារណាថាស្របគ្នានឹងលក្ខខណ្ឌតម្រូវនៃអនាគតិចៅក្រមឡើយ ទោះជាក្នុងករណីណាក៏ដោយ[81]។ អាស្រ័យហេតុដូច្នេះ ការវាយតម្លៃជាសត្យានុម័តត្រូវបានបំពេញក្នុងករណីនេះ ។

---

[75] សូមមើលកថាខណ្ឌទី៣ ខាងលើ( ខ្ញុំយល់ថាតួនាទីរបស់លោកនៅទីនេះ គឺតំណាង និងការពារកូនក្តីរបស់លោក។ សូមលោកតាំងសំណួរបន្ទាប់ ដែលពាក់ព័ន្ធនឹងការជំនុំជម្រះនេះ)។

[76] សូមមើលកថាខណ្ឌទី២ ខាងលើ។

[77] សូមមើលកថាខណ្ឌទី៣ ខាងលើ។

[78] សម្គាល់: ដូចនៅក្នុងករណី *Lavents*, គឺបណ្តឹងជិតចិត្តជាផ្នែក “សំណុំរឿង” របស់មេធាវីការពារក្តី។ សូមមើលកថាខណ្ឌទី ១៣ ខាងលើ។

[79] សូមមើល *Buscemi* and *Lavents* ។

[80] សូមមើលកថាខណ្ឌ ១២-១៤ ខាងលើ ។

[81] ដូចកថាខណ្ឌទី ១៣ ខាងលើ ។

**២ ម្យ៉ាងទៀត ឬជាជម្រើសមួយទៀត ការថ្លែងរបស់ ចៅក្រម Cartwright ទៅកាន់សារព័ត៌មាន នឹងនាំអ្នកសង្កេតការដែលមិនលំអៀង និងទទួលបានព័ត៌មានគ្រប់គ្រាន់ សន្និដ្ឋានបានថាចៅក្រមពុំមានអនាគតិគ្រប់គ្រាន់ដើម្បីបន្តតំណែងនៅអង្គជំនុំជម្រះសាលាដំបូងឡើយ**

22. ប្រសិនអង្គជំនុំជម្រះសាលាដំបូងខកខានមិនទទួលយកអត្ថិភាពនៃភាពលម្អៀងជាក់ស្តែងពីសំណាក់ចៅក្រម Cartwright នោះការប្រព្រឹត្តរបស់គាត់នឹងនាំឲ្យអ្នកសង្កេតការមិនលម្អៀង និងទទួលបានព័ត៌មានពេញលេញយល់ដឹងអំពីភាពលម្អៀងនេះ[82]។ ក្នុងករណីនេះ អ្នកសង្កេតការមិនលម្អៀងគឺជាបុគ្គលដែលទទួលបានព័ត៌មានពេញលេញដែលបានដឹងក្នុងចំណោមបញ្ហាដ៏ទៃទៀតអំពី៖ (i)ពាក្យសុំ និងសារណាផ្សេងៗដែលធ្វើឡើងដោយមេធាវីការពារក្តីតាំងពីមុនរហូតមកទល់បច្ចុប្បន្ននេះ ជាពិសេសសំណើកាលពីមុនរបស់មេធាវីការពារក្តីដែលបានដាក់តាមវិធាន៣៤ និង ៣៥[83] (ii) គោលជំហររបស់មេធាវីការពារក្តីទាក់ទងនឹងការជ្រៀតជ្រែកខាងនយោបាយនៅក្នុងតុលាការ និងកង្វះខាតជាក់ស្តែងរបស់ចៅក្រមអន្តរជាតិនូវការព្រួយបារម្ភទៅលើការជ្រៀតជ្រែករបស់រដ្ឋាភិបាលទៅក្នុងដំណើរការនីតិវិធីរបស់តុលាការ[84] និង (iii) ឥរិយាបថទូទៅរបស់ចៅក្រមចំពោះមេធាវីការពារក្តីនៅក្នុងតុលាការ ដែលរួមបញ្ចូលទាំងការបង្ហាញយ៉ាងច្បាស់ក្រឡែត និងជាបន្តបន្ទាប់អំពីការខកចិត្ត និងការមិនពេញចិត្តរបស់ចៅក្រម Cartwright ជាមួយនឹងគោលជំហដែលប្រកាន់យកដោយមេធាវីអន្តរជាតិ។ ដូចនៅក្នុងរឿងក្តី *Buscemi* និង *Olujic*ដែរ កត្តាដូចគ្នានេះដែលត្រូវបានពិភាក្សាក្នុងកថាទី១៩ និងទី២០ (ខាងលើ) នឹងផ្តល់ហេតុផលត្រឹមត្រូវជាសត្យានុម័តទៅការភ័យខ្លាចរបស់ នួន ជា ទាក់ទងនឹងអនាគតិរបស់ចៅក្រម Cartwright [85]។ ម្យ៉ាងវិញទៀត អ្នកសង្កេតការមិនលម្អៀង នឹង

---

[82] សាលក្រម Furundžija, កថាខណ្ឌ១៨៩។

[83] សូមមើល ឧទាហរណ៍ឯកសារ E.137/2 "ពាក្យសុំដិតចិត្តជាបន្ទាន់ប្រឆាំងនឹងចៅក្រម Cartwright ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១១ ។

[84] សូមមើលឧទាហរណ៍ ឯកសារ N E-116/1, បណ្តឹងសារទុក្ខភ្លាមប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងភាពត្រឹមត្រូវនៃការស៊ើបអង្កេត, ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១, ឯកសារ ERN 00746658-00746658។

[85] កថាខណ្ឌទី ១៤ ខាងលើ ។

ចាត់ទុកការថ្លែងរបស់ចៅក្រម Cartwright ទៅកាន់ប្រព័ន្ធផ្សព្វផ្សាយថា មានវិសមិតភាពជាមួយលក្ខខណ្ឌតម្រូវនៃអនាគតិតុលាការ[86]។ ដូច្នេះការវាយតម្លៃជាសត្យានុម័ត (ឬជាជម្រើសមួយទៀត) ក៏ត្រូវបានបំពេញផងដែរក្នុងករណីនេះ។

## ៣ អង្គជំនុំជម្រះសាលាដំបូងមិនត្រូវលើកលែង ឬ ជម្រុញការអនុវត្ត អ្វីដែលអនុវត្តទៅលើភាគីម្ខាង តែមិនអនុវត្តទៅលើភាគីផ្សេងទៀតនោះទេ

23. ថាតើពាក្យសំដីរបស់ចៅក្រម Cartwright ទៅកាន់ប្រព័ន្ធផ្សព្វផ្សាបំពេញបានការវាយតម្លៃជាសត្យានុម័ត ឬអត្តនោម័ត (ឬទាំងពីរ) យ៉ាងណានោះ ការអត្ថាធិប្បាយរបស់គាត់ច្បាស់ជាមិនត្រឹមត្រូវឡើយ។ ដូចដែលបានកត់សម្គាល់ម្តងទៀតដោយតុលាការ ECtHR អាជ្ញាធរតុលាការ "ត្រូវតែអនុវត្ត*ឆន្ទានុសិទ្ធិជាអតិបរមា* ទាក់ទងនឹងរឿងក្តីដែលកំពុងដោះស្រាយដើម្បីរក្សាមុខមាត់របស់គេជាចៅក្រមដែលឥតលម្អៀង[87]។ តាមពិតទៅប្រសិនបើ[ចៅក្រម] Cartwright យល់ឃើញថាវាជា*ការទទួលខុស*ត្រូវរបស់គាត់ដើម្បី [...] [ធានា] ថាតុលាការនេះត្រូវបានរៀបចំឡើងដោយមានលក្ខណៈជាអាជីពនិងស្មោះត្រង់[88] នោះគាត់មិនគម្បីបញ្ចេញគោលជំហជាសាធារណៈដែលមិនស្របទៅនឹង "ការទាមទារដ៏ខ្ពស់នៃយុត្តិធម៌ និងលក្ខណៈដ៏ខ្ពង់ខ្ពស់នៃមុខងារផ្នែកតុលាការ[របស់គាត់][89]។ ទោះបីចៅក្រម Cartwright មានភាពទៀងត្រង់នៅក្នុងតុលាការ វាហាក់ដូចជាថាចៅក្រម Cartwright មិនបានប្រកាន់ភ្ជាប់បទដ្ឋានខ្ពស់នៅក្រៅតុលាការឡើយ។ និយាយសាមញ្ញទៅ ឆន្ទានុសិទ្ធិតុលាការមិនត្រូវជម្រុញគាត់ឲ្យប្រើសារព័ត៌មានដើម្បីផលយកផលប្រយោជន៍ឡើយ[90] ។ ដោយសារតែការភ្លាំងភ្លាត់នេះ លោកស្រីចៅក្រមត្រូវតែបានដកចេញពីដំណើរការបន្តបន្ទាប់ទៀតក្នុងសំណុំរឿង ០០២។

---

[86] ដូចខាងលើ ។

[87] សូមមើលកថាខណ្ឌ១២ ខាងលើ ។

[88] សូមមើលកថាខណ្ឌ១២ ខាងលើ ។

[89] សូមមើលកថាខណ្ឌ១២ ខាងលើ ។

[90] សូមមើលកថាខណ្ឌ១២ ខាងលើ ។

## V. សេចក្តីសន្និដ្ឋាន

24. អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. ទួលយកពាក្យសុំប្តឹងដិតចិត្តនេះ ។

ខ. ជម្រុញឲ្យចៅក្រម Cartwright លាឈប់ពីមុខតំណែង អនុលោមមាត្រា ៥៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឬយ៉ាងហោចណាស់លាឈប់ពីមុខតំណែងដោយស្ម័គ្រចិត្តស្របតាមវិធាន៣៤(៥) ដោយរង់ចាំការសម្រេចលើបណ្តឹងដិតចិត្តនេះ ហើយតែងតាំងចៅក្រម Fenz ជំនួសកន្លែងទំនេរនេះ ។

គ. បង្គាប់ឲ្យមានការលាលែងជាបន្ទាន់ និងជាអចិន្ត្រៃយ៍នៃចៅក្រម Cartwright ពីការចូលរួមក្នុងដំណើរការនីតិវិធីបន្តបន្ទាប់ទៀតប្រឆាំងនិងលោក នួន ជា ក្នុងសំណុំរឿង ០០២។

ដោយពិចារណាលើលក្ខណៈនៃបណ្តឹងដិតចិត្តនេះ មេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកបណ្តឹងនេះជាបញ្ហាបន្ទាន់។

**សហមេធាវីការពារក្តីលោក នួន ជា**



**សុន អរុណ**



Michel PESTMAN & Victor KOPP